ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រុមប្រឹក្សាអាជ្ញាកណ្តាល
THE ARBITRATION COUNCIL

លេខ និង ឈ្មោះសំណុំរឿង៖ ១៩៥/១១-យីងដុង
កាលបរិច្ឆេទនៃសេចក្តីបង្គាប់៖ ថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០១១

# សេចក្តីបង្គាប់អាជ្ញាកណ្តាល

(ធ្វើឡើងស្របតាមមាត្រា ៣១៣ នៃច្បាប់ស្តីពីការងារ)

## សមាសភាពក្រុមអាជ្ញាកណ្តាល

អាជ្ញាកណ្តាលជ្រើសរើសឡើងដោយភាគីនិយោជក៖ អ៊ឹង សុទ្ធី
អាជ្ញាកណ្តាលជ្រើសរើសឡើងដោយភាគីកម្មករនិយោជិត៖ លីវ សុវណ្ណា
ប្រធានក្រុមអាជ្ញាកណ្តាលជ្រើសរើសឡើងដោយអាជ្ញាកណ្តាលទាំងពីរខាងលើ៖ ប៉ែន ប៊ុនឈា

## ភាគីនៃវិវាទ

### ១- ភាគីនិយោជក

ឈ្មោះ ៖ ក្រុមហ៊ុន យីង ដុង ស៊ូ ខូ អិលធីឌី
អាសយដ្ឋាន ៖ ភូមិបុរីសែនមនោរមន្យ សង្កាត់ចោមចៅ ខណ្ឌដង្កោ រាជធានីភ្នំពេញ
ទូរស័ព្ទ ៖ ០៩៩ ៦៧៨ ០៦៧ ទូរសារ ៖ គ្មាន
តំណាងភាគីនិយោជក ៖

- សវនាការលើកទី១ ៖
  - ១- លោក Liy Yi Zhong ប្រធានរដ្ឋបាល
  - ២- កញ្ញា Lim Kim Huoy រដ្ឋបាល
- សវនាការលើកទី២ ៖
  - ១- លោក Liy Yi Zhong ប្រធានរដ្ឋបាល
  - ២- កញ្ញា Lim Kim Huoy រដ្ឋបាល

### ២- ភាគីកម្មករនិយោជិត

ឈ្មោះ ៖ - សហព័ន្ធសហជីពខ្មែរ
- សហជីពខ្មែរ នៃរោងចក្រស្បែកជើង យីង ដុង


ផ្ទះលេខ ៧២ ផ្លូវលេខ ៥៩២ (កែងផ្លូវលេខ ៣២៧) សង្កាត់បឹងកក់ ២ ខណ្ឌទួលគោក រាជធានីភ្នំពេញ ។ ទូរស័ព្ទ/ទូរសារ៖ ៨៥៥-២៣ ៨៨១ ៨២៤
No. 72, Street 592 (corner of St. 327), Sangkat Boeung Kak II, Khan Tuol Kork, Phnom Penh• Tel/Fax: 855-23 881 824
E-mail: secretariat@arbitrationcouncil.org• Website: www.arbitrationcouncil.org

អាសយដ្ឋាន ៖ ភូមិបុរីសែនមនោរមន្យ សង្កាត់ចោមចៅ ខណ្ឌដង្កោ រាជធានីភ្នំពេញ

លេខទូរស័ព្ទ ៖ ០១២ ៦៥៨ ១២៩ ទូរសារ ៖ គ្មាន

តំណាងកម្មករនិយោជិតៈ

- សវនាការលើកទី១ ៖

| | |
|---|---|
| ១- លោក ជួន មុំធុល | ប្រធានសហព័ន្ធសហជីពខ្មែរ |
| ២- លោក មុំម ធន | អ្នកដោះស្រាយវិវាទសហព័ន្ធសហជីពខ្មែរ |
| ៣- កញ្ញា ញាណ ថងម៉ា | ប្រធានសហជីពខ្មែរ នៃរោងចក្រស្បែកជើង យឹង ដុង |
| ៤- អ្នកស្រី ឯក សារី | អនុប្រធានសហជីពខ្មែរ នៃរោងចក្រស្បែកជើង យឹង ដុង |
| ៥- អ្នកស្រី សៀម សុខលី | លេខាធិការសហជីពខ្មែរ នៃរោងចក្រស្បែកជើង យឹង ដុង |
| ៦- កញ្ញា ញាណ វណ្ណា | ជំនួយការសហជីព |
| ៧- កញ្ញា ឡាត់ សុម៉ាឡា | ជំនួយការដោះស្រាយវិវាទសហព័ន្ធសហជីពខ្មែរ |
| ៨- លោក ទេស សុផៃ | ជំនួយការដោះស្រាយវិវាទសហព័ន្ធសហជីពខ្មែរ |

- សវនាការលើកទី២ ៖

| | |
|---|---|
| ១- លោក ជួន មុំធុល | ប្រធានសហព័ន្ធសហជីពខ្មែរ |
| ២- លោក មុំម ធន | អ្នកដោះស្រាយវិវាទសហព័ន្ធសហជីពខ្មែរ |
| ៣- កញ្ញា ញាណ ថងម៉ា | ប្រធានសហជីពខ្មែរ នៃរោងចក្រស្បែកជើង យឹង ដុង |
| ៤- អ្នកស្រី ឯក សារី | អនុប្រធានសហជីពខ្មែរ នៃរោងចក្រស្បែកជើង យឹង ដុង |
| ៥- អ្នកស្រី សៀម សុខលី | លេខាធិការសហជីពខ្មែរ នៃរោងចក្រស្បែកជើង យឹង ដុង |

## បញ្ហាក្នុងវិវាទ

(នៅក្នុងរបាយការណ៍ផ្សះផ្សាមិនសះជា)

១- ទាមទារឱ្យក្រុមហ៊ុនទទួលយកថ្នាក់ដឹកនាសហជីពទាំងបីរូបមាន កញ្ញា ញាណ ថងម៉ា អ្នកស្រី សៀម សុខលី និងអ្នកស្រី ឯក សារី ឱ្យចូលធ្វើការវិញ និងបើកប្រាក់រំលឹក ហើយត្រូវបញ្ឈប់ការរើសអើងសហជីព (បង្កើតសហជីពថ្ងៃទី០៩ ខែតុលា ឆ្នាំ២០១១ ជូនដំណឹងមកក្រុមហ៊ុនថ្ងៃទី០៩ ខែតុលា ឆ្នាំ២០១១ សុំចុះបញ្ជិកានៅក្រសួងការងារ ថ្ងៃទី១០ ខែតុលា ឆ្នាំ២០១១)។

២- សុំឱ្យក្រុមហ៊ុនបង្កើតបន្ទប់ទារកដ្ឋាន និងបន្ទប់បំបៅដោះកូនឱ្យស្របតាមច្បាប់។ ក្នុងករណីបង្កើតមិនបាន សូមឱ្យក្រុមហ៊ុនផ្តល់ជាប្រាក់ជំនួសទារកដ្ឋានចំនួន ២០ ដុល្លារ ក្នុងមួយខែ ចំពោះស្ត្រីដែលមានការពាក់ព័ន្ធ។

៣- សុំឱ្យក្រុមហ៊ុនប្តូរប្រធានរដ្ឋបាលចេញ ព្រោះមិនចេះនិយាយភាសាខ្មែរ ពិបាកទំនាក់ទំនង និងធ្វើឱ្យមានជម្លោះកើតឡើង។



THE ARBITRATION COUNCIL

Chu

៤- សុំឱ្យក្រុមហ៊ុនបើកប្រាក់បញ្ចប់កិច្ចសន្យាការងារមានថិរវេលាកំណត់ឱ្យបានត្រឹមត្រូវ តាមច្បាប់ស្តីពីការងារ ។

៥- សុំឱ្យក្រុមហ៊ុនផ្តល់ទឹកបរិភោគប្រកបដោយអនាម័យ ដូចបុគ្គលិករដ្ឋបាលដែរ ។

៦- សុំឱ្យមានវេជ្ជបណ្ឌិតមួយនាក់ និងគ្រូពេទ្យមធ្យមមួយនាក់ទៀតព្រោះសព្វថ្ងៃក្រុមហ៊ុនមានកម្មករនិយោជិតជាង ១០០០ នាក់ ហើយមានគ្រូពេទ្យមធ្យមតែមួយនាក់ ។ សុំឱ្យក្រុមហ៊ុនរៀបចំបន្ទប់ពេទ្យបន្ថែមទៀតព្រោះបន្ទប់ពេទ្យនេះមានទំហំតូច ជាមួយគ្នានេះ ក៏សុំឱ្យមានថ្នាំពេទ្យសម្រាប់សង្គ្រោះបឋមដល់កម្មករនិយោជិតដែលគ្រោះថ្នាក់ការងារឱ្យបានគ្រប់គ្រាន់ផងដែរ ។

៧- សុំឱ្យក្រុមហ៊ុនបញ្ជូនឈ្មោះកម្មករជាង ១០០០ នាក់ ទៅនាយកដ្ឋានរបបសន្តិសុខសង្គម ព្រោះសព្វថ្ងៃមានកម្មករនិយោជិតជាង ៤០០ នាក់ប៉ុណ្ណោះ ដែលមានឈ្មោះនៅនាយកដ្ឋានរបបសន្តិសុខសង្គម ។

៨- សុំឱ្យក្រុមហ៊ុនធ្វើការបន្ថែមម៉ោងដោយអនុវត្តតាមគោលការណ៍ស្ម័គ្រចិត្ត និងថែមម៉ោងកុំឱ្យលើសពីពីរម៉ោង ក្នុងមួយថ្ងៃ (ជូនម៉ោង ១៩ យប់ ជូនម៉ោង ២១ យប់) ។

៩- សុំកុំឱ្យក្រុមហ៊ុនកាត់ប្រាក់ពីកម្មករនិយោជិត ពោលគឺ នៅកម្មករណាមានកំហុសបន្តិចបន្តួច កាត់ប្រាក់ចំនួន ១០ ដុល្លារអាមេរិក និងកម្មករនិយោជិតណាមានកំហុសធ្ងន់កាត់ប្រាក់ចំនួន ២០ ដុល្លារអាមេរិក ។

១០- សូមឱ្យកម្មករចិនសមាមាត្រជាមួយកម្មករខ្មែរ ព្រោះកម្មករចិនមានចំនួនជាង ២០ នាក់ លើសសមាមាត្រកំណត់បើប្រៀបធៀបទៅកម្មករខ្មែរសរុប ។

## អំណាចយុត្តាធិការរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល

ក្រុមប្រឹក្សាអាជ្ញាកណ្តាលទទួលអំណាចក្នុងការចេញសេចក្តីបង្គាប់នេះ ដោយយោងតាមជំពូកទី១២ ផ្នែក ទីពីរ(ខ)(មាត្រា ៣០៩ ដល់ ៣១៧) នៃច្បាប់ស្តីពីការងារឆ្នាំ១៩៩៧ ប្រកាសស្តីពីក្រុមប្រឹក្សាអាជ្ញាកណ្តាលលេខ ០៩៩ សកបយ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ វិធាននៃនីតិវិធីក្រុមប្រឹក្សាអាជ្ញាកណ្តាល ដែលភ្ជាប់ជាឧបសម្ព័ន្ធ នៃប្រកាសលេខ ០៩៩ សកបយ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ និងប្រកាសស្តីពីការតែងតាំងសមាជិកក្រុម ប្រឹក្សាអាជ្ញាកណ្តាលលេខ ១៣៦ កប/ប្រក ចុះថ្ងៃទី០៧ ខែមិថុនា ឆ្នាំ២០១១ (អាណត្តិទី៩) ។

ការព្យាយាមផ្សះផ្សាវិវាទការងាររួម ដែលជាកម្មវត្ថុនៃសេចក្តីបង្គាប់នេះ ត្រូវបានធ្វើឡើងស្របតាមជំពូកទី១២ ផ្នែកទី ២ (ក) នៃច្បាប់ស្តីពីការងារ ។ ប៉ុន្តែការផ្សះផ្សានោះ ភាគីទាំងពីរមិនបានឯកភាពសះជានឹងគ្នាឡើយ ហើយរបាយការណ៍ស្តីអំពីការមិនសះជាលេខ ១២៩១ កប/អក/វក ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០១១ ត្រូវបានបញ្ជូនមកលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល នៅថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០១១ ។

## សវនាការ និង សង្ខេបនីតិវិធី

ទីកន្លែងសវនាការ ៖ ក្រុមប្រឹក្សាអាជ្ញាកណ្តាល "ភូមិគ្រឹះលេខ ៧២ ផ្លូវលេខ ៥៩២ កាច់ជ្រុងផ្លូវលេខ ៣២៧ (ទល់មុខវិទ្យាល័យឥន្ទ្រទេវី), សង្កាត់បឹងកក់ ២, ខណ្ឌទួលគោក, រាជធានីភ្នំពេញ " ។

THE ARBITRATION COUNCIL

កាលបរិច្ឆេទសវនាការ ៖

- លើកទី១ ៖ ថ្ងៃទី ០២ ខែ ធ្នូ ឆ្នាំ ២០១១ (វេលាម៉ោង ០៨ និង ៣០ នាទី ព្រឹក) ។
- លើកទី២ ៖ ថ្ងៃទី ១៩ ខែ ធ្នូ ឆ្នាំ ២០១១ (វេលាម៉ោង ១៤ និង ០០ នាទី រសៀល) ។

បញ្ហានៃនីតិវិធី ៖

នៅថ្ងៃទី២៤ ខែតុលា ឆ្នាំ២០១១ នាយកដ្ឋានវិវាទការងារ បានទទួកពាក្យបណ្តឹងរបស់សហព័ន្ធសហជីពខ្មែរ លេខ ២៩៧/១១ សសខ ចុះថ្ងៃទី២០ ខែតុលា ឆ្នាំ២០១១ ស្តីពីការទាមទារឱ្យក្រុមហ៊ុនកែលំអលក្ខខណ្ឌការងារមួយចំនួនឱ្យបានល្អប្រសើរ។ បន្ទាប់ពីបានទទួលពាក្យបណ្តឹងមក នាយកដ្ឋានវិវាទការងារបានចាត់តាំងមន្ត្រីជំនាញធ្វើការដោះស្រាយវិវាទការងាររួមនេះជាបន្តបន្ទាប់ និងធ្វើការផ្សះផ្សាជាលើកចុងក្រោយ នៅថ្ងៃទី០៨ ខែវិច្ឆិកា ឆ្នាំ២០១១ ដោយទទួលបានលទ្ធផលមិនសះជានឹងគ្នាចំនួន ១០ ចំណុច លើការទាមទារចំនួន ១០ ចំណុច។ ចំណុចមិនសះជាចំនួន ១០ ចំណុចនេះ ត្រូវបានបញ្ជូនមកក្រុមប្រឹក្សាអាជ្ញាកណ្តាល នៅថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០១១ តាមរបាយការណ៍ស្តីពីការដោះស្រាយវិវាទការងាររួមមិនសះជា ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០១១។ បន្ទាប់ពីបានទទួលសំណុំរឿងរួចមក លេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាលបានធ្វើការកោះអញ្ជើញភាគីនិយោជក និងភាគីកម្មករនិយោជិតមកសវនាការ និងធ្វើការផ្សះផ្សាលើករណីមិនសះជាចំនួន ១០ ចំណុចនេះ នៅថ្ងៃទី២ ខែធ្នូ ឆ្នាំ២០១១ វេលាម៉ោង ៨ និង ៣០ នាទី ព្រឹក ចំពោះសវនាការលើកទី១ និង នៅថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០១១ វេលាម៉ោង ២ និង ០០ នាទី រសៀល ចំពោះសវនាការទី២។ ភាគីទាំងពីរមានវត្តមាន តាមការកោះអញ្ជើញរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាលទាំងសវនាការលើកទី១ និង សវនាការលើកទី២។ ប៉ុន្តែ ដោយពុំទាន់មានបញ្ជីកាសហជីពខ្មែរ និង មិនមានលិខិតពឹងពាក់ជាលាយលក្ខ័អក្សរ ពីកម្មករនិយោជិតផ្សេងទៀត ដូចនេះហើយ ទើបកម្មករនិយោជិតបានសំរេចចិត្ត សុំដកចំណុចវិវាទទី២ ចំណុចវិវាទទី៣ ចំណុចវិវាទទី៤ ចំណុចវិវាទទី៥ ចំណុចវិវាទទី៦ ចំណុចវិវាទទី៧ ចំណុចវិវាទទី៨ ចំណុចវិវាទទី៩ និងចំណុចវិវាទទី១០។ សរុបមក គឺសល់តែចំណុចវិវាទទី១ តែប៉ុណ្ណោះ ដែលក្រុមប្រឹក្សាអាជ្ញាកណ្តាលបានធ្វើការផ្សះផ្សា និងបានព្យាយាមសួររកនូវព័ត៌មានផ្សេងៗបន្ថែមទៀត ដែលទាក់ទងទៅនឹងមិនសះជាចំនួនសរុប ០១ ចំណុចនេះ តែមិនបានទទួលលទ្ធផលសះជាឡើយ។ ចំពោះសេចក្តីបង្គាប់ត្រូវ បានពន្យាដោយមានការយល់ព្រមពីគូភាគី ហើយក្រុមប្រឹក្សាអាជ្ញាកណ្តាលនឹងចេញសេចក្តីបង្គាប់នៅថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០១១។

ដោយសារភាគីទាំងពីរជាហត្ថលេខីនៃអនុស្សារណៈនៃការយោគយល់គ្នា ចុះថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ២០១០ ស្តីពីការធ្វើឱ្យប្រសើរឡើងនូវទំនាក់ទំនងវិជ្ជាជីវៈក្នុងឧស្សាហកម្មកាត់ដេរសំលៀកបំពាក់ ដូចនេះ ក្នុងសំណុំរឿងនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលនឹងបែងចែកសេចក្តីសម្រេចនៃចំណុចវិវាទជាពីរ គឺចំណុចវិវាទអំពីសិទ្ធិ និងចំណុចវិវាទអំពីប្រយោជន៍។ ភាគីទាំងពីរមិនមានសិទ្ធិប្តឹងជំទាស់លើសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាលលើចំណុចវិវាទអំពីសិទ្ធិនោះទេ ព្រោះភាគីទាំងពីរបានព្រមព្រៀងគ្នា ឱ្យសេចក្តីសម្រេចនេះជាសេចក្តីសម្រេច ដែលជាប់កាតព្វកិច្ច តាមរយៈអនុស្សារណៈនៃការយោគយល់គ្នាចុះថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ២០១០ រួចហើយ។ ប៉ុន្តែ ភាគីអាចប្តឹងជំទាស់ទៅលើសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាលលើវិវាទអំពីប្រយោជន៍ ប្រសិនបើភាគីជ្រើសរើសយកសេចក្តីសម្រេចមិនជាប់កាតព្វកិច្ចចំពោះវិវាទអំពីប្រយោជន៍។ ការប្តឹងជំទាស់របស់ភាគីទៅនឹងសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាអាជ្ញា



THE ARBITRATION COUNCIL

កណ្ដាលលើចំណុចវិវាទអំពីប្រយោជន៍ និងមិនបណ្ដាលឱ្យប៉ះពាល់ទៅដល់កាតព្វកិច្ចក្នុងការអនុវត្តសេចក្ដីសម្រេច ដែលជាវិវាទអំពីសិទ្ធិទេ ដោយអនុលោមតាមស្មារតីនៃអនុស្សារណៈនៃការយោគយល់គ្នាខាងលើនោះ។ ក្នុងសំណុំរឿងនេះ ភាគីទាំងពីរជ្រើសរើសយកសេចក្ដីបង្គាប់មិនជាប់កាតព្វកិច្ចលើចំណុចវិវាទអំពីប្រយោជន៍។

ដូច្នេះ ក្រុមប្រឹក្សាអាជ្ញាកណ្ដាលធ្វើការពិចារណា និងដោះស្រាយលើចំណុចវិវាទខាងលើនេះ ដោយផ្អែកលើភស្តុតាង និងការរកឃើញនៃអង្គហេតុ ដូចខាងក្រោមៈ

**ភស្តុតាង**

សាក្សី និង អ្នកជំនាញក្រៅពីភាគី ៖ គ្មាន

**ឯកសារ ភស្តុតាង ដែលក្រុមអាជ្ញាកណ្ដាលយកមកពិចារណាមាន**

ក- ឯកសារបានទទួលពីភាគីនិយោជក ៖

១- លិខិតផ្ទេរសិទ្ធិរបស់រោងចក្រផលិតស្បែកជើង យីងដុង ផ្ទេរសិទ្ធិជូន លោក លីវ អ៊ីចុង ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០១១។

២- កំណត់ហេតុនៃការផ្សះផ្សាវិវាទការងាររួមរបស់ក្រុមហ៊ុន យីង ដុង ចុះថ្ងៃទី០៨ ខែវិច្ឆិកា ឆ្នាំ២០១១ ។

៣- លិខិតលេខ ១១៦០ ក.ប/អក/វក ចុះថ្ងៃទី១៩ ខែតុលា ឆ្នាំ២០១១ របស់ប្រធាននាយកដ្ឋានវិវាទការងារ ជម្រាបមក កញ្ញា ញាណ ថងម៉ា ស្ដីពីការចុះបញ្ជិកាសហជីពខ្មែរ នៃរោងចក្រស្បែកជើង យីង ដុង។

៤- លិខិតលេខ ១៣០៤ ក.ប/អក/វក ចុះថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០១១ របស់ប្រធាននាយកដ្ឋានវិវាទការងារ ជម្រាបមក លោកនាយកក្រុមហ៊ុន យីង ដុង ស្ដីពីការចុះបញ្ជិកាសហជីពខ្មែរ នៃរោងចក្រស្បែកជើង យីង ដុង។

៥- លិខិតលេខ ១៣១៩ ក.ប/អក/វក ចុះថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០១១ របស់ប្រធាននាយកដ្ឋានវិវាទការងារ ជម្រាបមក ប្រធានសហព័ន្ធសហជីពខ្មែរ ស្ដីពីការចុះបញ្ជិកាសហជីពខ្មែរ នៃរោងចក្រស្បែកជើង យីង ដុង។

៦- វិញ្ញាបនប័ត្របញ្ជាក់ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម របស់ក្រុមហ៊ុន យីង ដុង ស៊ូ ខូ អិលធីឌី លេខ ៤៨១៥ ពណ.ចបព ចុះថ្ងៃទី០៧ ខែធ្នូ ឆ្នាំ២០១១។

៧- លិខិតលេខ ៤៨១៥ ពណ.ចបព ចុះថ្ងៃទី០៧ ខែធ្នូ ឆ្នាំ២០១១ របស់ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម សូមបញ្ជាក់ថា ក្រុមហ៊ុន យីង ដុង ស៊ូ ខូ អិលធីឌី ជាក្រុមហ៊ុនវិនិយោគទុនឯកជនមួយ ត្រូវបានចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់ គិតចាប់ពីកាលបរិច្ឆេទនៃការចុះបញ្ជីនេះតទៅ។

៨- លក្ខន្តិកៈរបស់ក្រុមហ៊ុន យីង ដុង ស៊ូ ខូ អិលធីឌី ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០០៩។

៩- បទបញ្ជាផ្ទៃក្នុងរបស់ក្រុមហ៊ុនផលិតស្បែកជើង យីង ដុង ខូ អិលធីឌី ។

១០- កិច្ចសន្យាការងារកម្មករ (ពេញសិទ្ធិ) របស់ឈ្មោះ ស៊ា ម៉ា។

១១- កិច្ចសន្យាការងារកម្មករ (ពេញសិទ្ធិ) របស់ឈ្មោះ ឯម សារី។

១២- កិច្ចសន្យាការងារកម្មករ (ពេញសិទ្ធិ) របស់ឈ្មោះ សៀម សុខលី។

១៣- អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ របស់ឈ្មោះ ញាណ ថងម៉ា ចុះថ្ងៃទី២៣ ខែមីនា ឆ្នាំ២០០៧។

១៤- សេចក្តីជូនដំណឹងរបស់ក្រុមហ៊ុន ចុះថ្ងៃទី២២ ខែតុលា ឆ្នាំ២០១១ ស្តីពីការបញ្ឈប់ឈ្មោះ អ៊ី ស៊ៀវភិង សៀម សុខលី និង ឯក សារី។

១៥- លិខិតបញ្ជាក់របស់កម្មករឈ្មោះ អ៊ី ស៊ីណា, ហៃល ចាន់ថា, ឆេង ស្រីណោង, ស៊ិន កែសី, អ៊ុំ ស្រីម៉ាច, ចក ជីឆេង, ចេម ស្រី, ប៊ិន ផល្លា, ជួន សុភា, សឹង ស៊ីម៉ាច, ជិន សាមី និង ជួន លាប ដែលបញ្ជាក់ថា ឈ្មោះ ញាណ ថងម៉ា បានហៅពួកយើងខ្ញុំ ចូលជាសមាជិកសហជីពថ្មីរបស់គាត់។

១៦- តារាងប្រាក់បៀវត្សសំរាប់ខែវិច្ឆិកា ឆ្នាំ២០១១ របស់ឈ្មោះ ស៊ាវ ម៉ា, សៀវ សុខលី និង ឯក សារី។

ខ- ឯកសារបានទទួលពីភាគីកម្មករនិយោជិត ៖

១- បង្កាន់ដៃទទួលសំណុំរឿង របស់នាយកដ្ឋានវិវាទការងារ នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ស្តីពីការសុំចុះបញ្ជីការសហជីពខ្មែរ នៃក្រុមហ៊ុន យីង ដុង ចុះថ្ងៃទី១៤ ខែតុលា ឆ្នាំ២០១១។

២- បញ្ជីវត្តមានអ្នកចូលរួមបោះឆ្នោតជ្រើសរើសថ្នាក់ដឹកនាំសហជីពខ្មែរ នៃរោងចក្រស្បែកជើង យីង ដុង។

៣- សេចក្តីចម្លងសំបុត្របញ្ជាក់កំណើត របស់ឈ្មោះ ញាណ ថងម៉ា ចុះថ្ងៃទី២៨ ខែតុលា ឆ្នាំ២០១១។

៤- អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ របស់ឈ្មោះ ញាណ ថងម៉ា ចុះថ្ងៃទី០២ ខែវិច្ឆិកា ឆ្នាំ២០១១។

៥- លិខិតជូនដំណឹងរបស់សហព័ន្ធសហជីពខ្មែរ គោរពជូន លោកនាយកក្រុមហ៊ុន យីង ដុង លេខ ២៤៣/១១ សសខ ចុះថ្ងៃទី១០ ខែតុលា ឆ្នាំ២០១១។

គ- ឯកសារបានទទួលពីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

១- របាយការណ៍ស្តីពីការដោះស្រាយវិវាទការងាររួមនៅក្រុមហ៊ុន យីង ដុង លេខ ១២៩១ កប/អក/វក ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០១១ ។

២- កំណត់ហេតុនៃការផ្សះផ្សាវិវាទការងាររួមរបស់ក្រុមហ៊ុន យីង ដុង ចុះថ្ងៃទី០៨ ខែវិច្ឆិកា ឆ្នាំ២០១១ ។

ឃ- ឯកសារបានទទួលពីលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល

១- លិខិតអញ្ជើញភាគីនិយោជកចូលរួមសវនាការ លេខ ៨៩១ កប/អក/វក/លកអ. ចុះថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០១១ ។

២- លិខិតអញ្ជើញភាគីកម្មករនិយោជិតចូលរួមសវនាការ លេខ ៨៩២ កប/អក/វក/លកអ. ចុះថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០១១ ។

៣- លិខិតអញ្ជើញភាគីនិយោជកចូលរួមសវនាការលើកទី២ លេខ ៨៩១ កប/អក/វក/លកអ. ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០១១ ។

៤- លិខិតអញ្ជើញភាគីកម្មករនិយោជិតចូលរួមសវនាការលើកទី២ លេខ ៨៩២ កប/អក/វក/លកអ. ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០១១ ។

៥- ការព្រមព្រៀងយកសេចក្តីបង្គាប់ជាប់កាតព្វកិច្ចលើចំណុចវិវាទអំពីសិទ្ធិ ចុះថ្ងៃទី០២ ខែធ្នូ ឆ្នាំ២០១១ ។

**អង្គហេតុ**

- ក្រោយពីបានពិនិត្យរបាយការណ៍នៃការផ្សះផ្សាវិវាទការងាររួម
- ក្រោយពីបានស្តាប់អំណះអំណាងរបស់តំណាងភាគីកម្មករនិយោជិត និង ភាគីនិយោជក
- ក្រោយពីបានពិនិត្យឯកសារបន្ថែម

ក្រុមប្រឹក្សាអាជ្ញាកណ្តាលរកឃើញថា ៖

- ក្រុមហ៊ុន យីង ដុង ស៊ូ ខូ អិលធីឌី ជាប្រភេទក្រុមហ៊ុនផលិតផលស្បែកជើង ដែលមានជួលកម្មករនិយោជិតប្រហែលចំនួន ១000 នាក់។
- សហជីពខ្មែរជាភាគីដើមបណ្តឹងនៅក្នុងសំណុំរឿងនេះ។ សហជីពនេះពុំទាន់មានបញ្ជិកាពីក្រសួងការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈទេ តែទទួលបានបង្កាន់ដៃសុំចុះបញ្ជិកានៅថ្ងៃទី១៤ ខែតុលា ឆ្នាំ២០១១។

ចំណុចវិវាទ១ ៖ កម្មករនិយោជិតទាមទារឱ្យទាមទារឱ្យក្រុមហ៊ុនទទួលយកថ្នាក់ដឹកនាំសហជីពទាំងបីរូប មាន កម្មការិនី ញាណ ថងម៉ា កម្មការិនី សៀម សុខលី និងកម្មការិនី ឯក សារី ឱ្យចូលធ្វើការវិញ ព្រមទាំងគិតរំលឹកប្រាក់ឈ្នួល ចាប់ពីថ្ងៃបញ្ឈប់ រហូតដល់ថ្ងៃចូលធ្វើការវិញ និងត្រូវបញ្ឈប់ការរើសអើងសហជីព

- កម្មការិនី ឯក សារី
  - កម្មការិនី ឯក សារី បានចូលមកធ្វើការនៅក្រុមហ៊ុន ថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០០៩ ក្នុងតួនាទីជាកម្មករខាងស៊េរី (ជាវស្បែកជើង) និងបានប្រាក់ឈ្នួលប្រហែល ៩០ ដុល្លារអាមេរិក ក្នុងមួយខែ។ គាត់មានកិច្ចសន្យាដែលមានកំណត់ថិរវេលា គឺមានន័យថា កម្មការិនី ឯក សារី ចុះកិច្ចសន្យារាល់ ៦ ខែម្តង។ កិច្ចសន្យាការងារចុងក្រោយរបស់គាត់ គឺចាប់ពីថ្ងៃទី០១ ខែមេសា ឆ្នាំ ២០១១ និងដល់ថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០១១។ ហើយចាប់ពីថ្ងៃទី០១ ខែតុលា ឆ្នាំ២០១១ ទៅ គឺគាត់នៅបន្តធ្វើការឱ្យនិយោជកតែមិនមានកិច្ចសន្យាការងារអ្វីទេ។
  - កម្មការិនី ឯក សារី បញ្ជាក់ថា គាត់ពុំដែលត្រូវបាននិយោជកព្រមានទេ ។
- កម្មការិនី ញាណ ថងម៉ា
  - កម្មការិនី ញាណ ថងម៉ា បានចូលមកធ្វើការនៅថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០០៩ ដោយមានតួនាទីជាអ្នកបកប្រែ ដោយទទួលបានប្រាក់ឈ្នួលសរុបចំនួន ២២៦ ដុល្លារអាមេរិក។ កម្មការិនីឈ្មោះ ញាណ ថងម៉ា មានកិច្ចសន្យាដែលមានកំណត់ថិរវេលាចំនួន ៦ ខែម្តង ហើយកិច្ចសន្យាការងាររបស់គាត់ត្រូវបានបន្តជាបន្ត

បន្ទាប់។ កិច្ចសន្យាចុងក្រោយ របស់គាត់គឺនៅថ្ងៃទី០១ ខែមេសា ឆ្នាំ២០១១ និងត្រូវបញ្ចប់នៅថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០១១។ ហើយចាប់ពីថ្ងៃទី០១ ខែតុលា ឆ្នាំ២០១១ ទៅគឺគាត់នៅបន្តធ្វើការឱ្យនិយោជក តែមិនមានកិច្ចសន្យាការងារអ្វីទេ។

- ភាគីនិយោជកបានបញ្ជាក់ថា កម្មការិនី ញាណ ផងម៉ា បានធ្វើលិខិតលាឈប់ នៅថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០១១។ កម្មការិនី ញាណ ផងម៉ា បានបញ្ជាក់ថា ខ្លួនពិតជាបានធ្វើលិខិតលាឈប់នៅថ្ងៃទី១៤ ខែ កក្កដា ឆ្នាំ២០១១ មែន ប៉ុន្តែប្រធានផ្នែករបស់ខ្លួនបានហៅមកធ្វើការវិញ ដោយមានកិច្ចសន្យាផ្ទាល់មាត់ បន្ទាប់ពីបានឈប់សម្រាក ១សប្តាហ៍។ ភាគីនិយោជកមិនជំទាស់នឹងការលើកឡើងនេះទេ។ ដូច្នេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា កម្មការិនី ញាណ ផងម៉ា បានចូលធ្វើការវិញ ដោយមិនមានចុះកិច្ចសន្យាការងារនោះទេ។
- កម្មការិនី ញាណ ផងម៉ា បានបញ្ជាក់ថា ប្រាក់ឈ្នួលខែកក្កដា ខែសីហា គឺគាត់បានបើក តែប្រាក់ឈ្នួលខែកញ្ញា មិនទាន់បានបើកទេ ដោយសារប្រាក់ឈ្នួលខែកញ្ញា ត្រូវបើកនៅខែតុលា។
- ភាគីនិយោជកបានបញ្ជាក់ថា ប្រាក់ឈ្នួលខែកក្កដា ខែសីហា និងខែកញ្ញា គឺនិយោជកបានបើកឱ្យហើយ។ កម្មការិនី ញាណ ផងម៉ា បានបញ្ជាក់ថា ចាប់តាំងពីធ្វើការមក គាត់មិនដែលត្រូវបានក្រុមហ៊ុនព្រមានទេ។

• កម្មការិនី សៀម សុខលី

- កម្មការិនី សៀម សុខលី បានចូលមកធ្វើការនៅក្រុមហ៊ុន ថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០១០ ក្នុងតួនាទីជាកម្មករខាងឃ្លាំង និងបានប្រាក់ឈ្នួលប្រហែល ១១០ ដុល្លារអាមេរិក ក្នុងមួយខែ។ គាត់មានកិច្ចសន្យាការងារដែលមានកំណត់ថិរវេលា គឺមានន័យថា កម្មការិនី សៀម សុខលី ចុះកិច្ចសន្យារាល់ ៦ ខែម្តង។ កិច្ចសន្យាការងារចុងក្រោយរបស់គាត់ គឺចាប់ពីថ្ងៃទី០១ ខែមេសា ឆ្នាំ២០១១ និងដល់ថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០១១។ ហើយចាប់ពី ថ្ងៃទី០១ ខែតុលា ឆ្នាំ២០១១ ទៅគឺគាត់នៅបន្តធ្វើការឱ្យនិយោជកតែមិនមានកិច្ចសន្យាការងារអ្វីទេ។
- កម្មការិនី សៀម សុខលី បានបញ្ជាក់ថា គាត់ធ្លាប់បានទទួលលិខិតព្រមានចំនួន ២ ដង គឺទី១ នៅខែកុម្ភៈ ឆ្នាំ២០១១ និង លើកទី២ នៅខែមីនា ឆ្នាំ២០១១ ដោយសារការ និយាយទូរស័ព្ទ និងស្តាប់ចំរៀងតាមកាសនៅពេលម៉ោងធ្វើការ។

❖ ទាក់ទងនឹងការបញ្ឈប់ ៖

- នៅថ្ងៃទី០៩ ខែតុលា ឆ្នាំ២០១១ សហជីពខ្មែរបានបោះឆ្នោតជ្រើសរើសថ្នាក់ដឹកនាំសហជីព ដោយមាន (១)កម្មការិនី ញាណ ផងម៉ា ជាប់ជាប្រធានសហជីព (២) កម្មការិនី ឯក សារី ជាប់ជាអនុប្រធានសហជីព (៣) កម្មការិនី សៀម សុខលី ជាប់ជាលេខាធិការសហជីព។
- សហជីពបានផ្ញើលិខិតជូនដំណឹងអំពីលទ្ធផលបោះឆ្នោតទៅនិយោជក នៅថ្ងៃទី១០ ខែតុលា ឆ្នាំ២០១១។ រដ្ឋបាលក្រុមហ៊ុនមិនបានទទួលយកលិខិតនោះទេ ប៉ុន្តែគាត់បានសុំយកលិខិតនោះទៅថតចំលង រួចហើយ

ប្រគល់ឱ្យសហជីពវិញ ។ ភាគីនិយោជកមិនជំទាស់នឹងការលើកឡើងនេះទេ ។

- ដោយសារនិយោជកមិនព្រមទទួលយកលិខិតនៅថ្ងៃទី១៤ ខែតុលា ឆ្នាំ២០១១ ភាគីសហជីពបានផ្ញើលទ្ធផល បោះឆ្នោតនេះតាមរយៈប្រៃសណីយ៍ ។
- នៅថ្ងៃទី១៤ ខែតុលា ឆ្នាំ២០១១ សហជីពទទួលបានបង្កាន់ដៃសុំចុះបញ្ជិកាពីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ។
- នៅថ្ងៃទី១៧ ខែតុលា ឆ្នាំ២០១១ និយោជកបានផ្ញើលិខិតជំទាស់អំពីការស្នើសុំចុះបញ្ជិការបស់សហជីពខ្មែរទៅក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ព្រោះបេក្ខភាពថ្នាក់ដឹកនាំឈ្មោះ ញាណ ថងម៉ា មានអាយុមិនគ្រប់ គឺអាយុ ២៤ឆ្នាំ តាមអត្តសញ្ញាប័ណ្ណ ។
- នៅថ្ងៃទី១៩ ខែតុលា ឆ្នាំ២០១១ នាយកដ្ឋានវិវាទការងារ បានជម្រាបមកកម្មការិនីឈ្មោះ ញាណ ថងម៉ា ថា អំពីការមិនអាចរៀបចំសំណុំរឿងជូនក្រសួងដើម្បីសុំចុះបញ្ជិកាសហជីពខ្មែររបស់កម្មការិនី ញាណ ថងម៉ា ដរាបណាកម្មការិនី ញាណ ថងម៉ា មានភស្តុតាងច្បាស់លាស់បង្ហាញនាយកដ្ឋានវិវាទការងារអំពីភាពត្រឹមត្រូវរបស់ខ្លួន ទើបនាកយដ្ឋានវិវាទការងាររៀបចំសំណុំរឿងនេះជូនក្រសួងការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈពិនិត្យ និងសំរេច ។
- នៅថ្ងៃទី២២ ខែតុលា ឆ្នាំ២០១១ វេលាម៉ោង ៩ ព្រឹក និយោជកបានហៅកម្មករនិយោជិតទាំងបី ទៅជួបនៅបន្ទប់ប្រជុំ ដោយមានសន្តិសុខ២នាក់ និងប៉េអឹម២នាក់ អមដំណើរទៅជាមួយ ។ ប្រធានខ្សែផលិតកម្មបានប្រគល់សេចក្តីជូនដំណឹងថា កម្មការិនីទាំងបីថា ត្រូវបានបញ្ឈប់ពីការងារហើយ ដោយសារការងាររបស់គាត់មិនរីកចំរើន នៅក្នុងម៉ោធ្វើការមិនព្រមធ្វើការឱ្យបានល្អ និងចេះតែហៅកម្មករនិយោជិតឱ្យចូលសហជីពខ្លួន និងបង្កើតសហជីពមិនស្របតាមច្បាប់ ។
- នៅថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០១១ នាយកដ្ឋានវិវាទការងារបានជម្រាបមកនិយោជកថា ប្រសិនបើនិយោជកមិនមានភស្តុតាង ឬ ឯកសារណាមួយបញ្ជាក់បន្ថែមទេ នាយកដ្ឋាននឹងរៀបចំសំណុំរឿងជូនក្រសួងការងារដើម្បីចុះបញ្ជិកា ។
- នៅថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០១១ នាយកដ្ឋានវិវាទការងារ បានជម្រាបមកប្រធានសហព័ន្ធសហជីពខ្មែរថា នៅពេលដែលសហជីពមានភស្តុតាងច្បាស់លាស់បង្ហាញមកនាយកដ្ឋានអំពីភាពត្រឹមត្រូវរបស់ខ្លួននាយកដ្ឋាននឹងរៀបចំសំណុំរឿងជូនក្រសួងពិនិត្យសម្រេចតាមការជាក់ស្តែង ។
- ភាគីនិយោជកបញ្ជាក់ថា ការបញ្ឈប់កម្មករនិយោជិតទាំង ៣ នាក់នេះ គឺ និយោជកមិនបានសុំការអនុញ្ញាតពីអធិការការងារទេ ។
- នៅក្នុងសវនាការ ភាគីនិយោជកបានផ្តល់សេចក្តីជូនដំណឹងទាក់ទងនឹងការបញ្ឈប់ កម្មការិនី ញាណ ថងម៉ា និង កម្មការិនី សៀម សុខលី និងកម្មការិនី ឯក សារី មកក្រុមប្រឹក្សាអាជ្ញាកណ្តាល ។ ក្នុងសេចក្តីជូនដំណឹងនេះ បានបញ្ជាក់ថា កម្មការិនីទាំងបីនេះធ្វើការមិនរីកចំរើន ហើយម៉ោងធ្វើការមិនព្រមធ្វើឱ្យបានល្អ ។

ម្យ៉ាងវិញទៀត នាំគ្នាបង្កើតសហជីព ហើយនាំកម្មករនិយោជិតដទៃទៀតចូលសមាជិកខ្លួននៅម៉ោងការងារ ដែលបង្កើតឱ្យមានភាពរញ៉េរញ៉ៃពេលម៉ោងធ្វើការ ។

❖ អំណះអំណាងរបស់ភាគីនិយោជក និងភាគីកម្មករនិយោជិត ៖

- ភាគីនិយោជកបញ្ជាក់ថា និយោជកពិតជាបានបញ្ឈប់ការងាររបស់កម្មការិនីទាំង ៣ នាក់ ព្រោះថាកម្មការិនីទាំងបីនេះ បានប្រព្រឹត្តកំហុសដូចមានចែងក្នុងមាត្រា ៨៣ (៥) នៃច្បាប់ស្តីពីការងារ ដោយសារកម្មករនិយោជិតទាំង ៣ នាក់ បានហៅកម្មកនិយោជិតឱ្យចូលសមាជិកសហជីព នាំឱ្យមានភាពរញ៉េរញ៉ៃនៅកន្លែងធ្វើការ ។
- កម្មការិនី ញាណ ផងម៉ា កម្មការិនី សៀម សុខលី និងកម្មការិនី ឯក សារី បានធ្វើការអះអាងថា ពួកខ្លួននិយាយពីរឿងសហជីព និងសកម្មភាពមួយចំនួនរបស់សហជីព តែនៅពេលបាយថ្ងៃត្រង់ប៉ុណ្ណោះ ។ ចំពោះម៉ោងធ្វើការវិញ គឺមិនដែលបាននិយាយពីរឿងសហជីពម្តងណាឡើយ ។ រាល់ការនិយាយស្តីគ្នាក្នុងម៉ោងធ្វើការ គឺត្រូវបានប្រធានផ្នែកមកស្តីឱ្យ រឺ ធ្វើការព្រមានទៀតក៏មាន ។
- កម្មការិនី ញាណ ផងម៉ា កម្មការិនី សៀម សុខលី និងកម្មការិនី ឯក សារី បានធ្វើការអះអាងថា ការបញ្ឈប់ពួកគាត់ទាំង ៣ នាក់នេះ មានការរើសអើងសហជីព ដោយសារតែពួកគាត់ជាថ្នាក់ដឹកនាំរបស់សហជីពខ្មែរ ។

**ហេតុផលនៃសេចក្តីសម្រេច ÷**

ចំណុចវិវាទ១ ៖ កម្មករនិយោជិតទាមទារឱ្យទាមទារឱ្យក្រុមហ៊ុនទទួលយកថ្នាក់ដឹកនាសហជីពទាំងបីរូប មាន កម្មការិនី ញាណ ផងម៉ា កម្មការិនី សៀម សុខលី និងកម្មការិនី ឯក សារី ឱ្យចូលធ្វើការវិញ ព្រមទាំងគិតរំលឹកប្រាក់ឈ្នួល ចាប់ពីថ្ងៃបញ្ឈប់ រហូតដល់ថ្ងៃចូលធ្វើការវិញ និងត្រូវបញ្ឈប់ការរើសអើងសហជីព

មុននឹងពិចារណាចំណុចវិវាទនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលពិចារណាថា តើចំណុចវិវាទនេះ ជាវិវាទអំពីសិទ្ធិដែរ ឬទេ?

ក្នុងសំណុំរឿងមុនៗ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា *"វិវាទអំពីសិទ្ធិ គឺជាវិវាទទាក់ទងនឹងសិទ្ធិដែលមានចែងក្នុងច្បាប់ កិច្ចព្រមព្រៀង ឬអនុសញ្ញារូបណាមួយចែងពីការទាមទារនោះ"* ។ (សូមមើលសេចក្តីបង្គាប់អាជ្ញាកណ្តាលលេខ *០៥/១១-អ៊ីម វ៉េ (សាខាទី១) ហេតុផលចំណុចវិវាទទី១ និង៥, លេខ ១៣/១១-ហ្គូល ការ៉ឺម៉ិច ហេតុផលចំណុចវិវាទទី១ និង២ និងលេខ ១៤/១១-ជី អេច ជី ហេតុផល ចំណុចវិវាទទី៤*) ។

ក្រុមប្រឹក្សាអាជ្ញាកណ្តាលនៅក្នុងសំណុំរឿងនេះ ក៏យល់ស្របនឹងការបកស្រាយរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាលនៅក្នុងសំណុំរឿងខាងលើដែរ ។ ក្នុងករណីនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលរកឃើញថា ចំណុចវិវាទនេះ គឺជាវិវាទអំពីសិទ្ធិ ព្រោះវិវាទនេះពាក់ព័ន្ធនឹងការការបញ្ឈប់ថ្នាក់ដឹកនាំសហជីព ដែលមានចែងក្នុងមាត្រា ២៩៣ នៃច្បាប់ស្តីពីការងារ និង ប្រកាសលេខ ៣០៥ និងការបញ្ឈប់ការរើសអើងសហជីព ដែលមានចែងក្នុងមាត្រា ១២ និង មាត្រា ២៧៩ នៃច្បាប់ស្តីពីការងារ ។ ដូចនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលនឹងពិចារណាចំណុចវិវាទនេះ ដូចខាងក្រោម ៖

THE ARBITRATION COUNCIL

ក្រុមប្រឹក្សាអាជ្ញាកណ្តាលនឹងបន្តធ្វើការពិចារណាថា តើនិយោជកបានបញ្ឈប់កម្មករនិយោជិតទាំង៣នេះ ត្រឹមត្រូវតាមច្បាប់ស្តីពីការងារដែរ ឬទេ?

ប្រការ៤ កថាខណ្ឌទី១ នៃប្រកាសលេខ ៣០៥ សកបយ ចុះថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០០១ ចែងថា *"ចាប់តាំងពីពេលដាក់ពាក្យចុះបញ្ជីកាសហជីពកម្មករនិយោជិតទាំងអស់ ដែលជាស្ថាបនិក ឬ កម្មករនិយោជិតដែលស្ម័គ្រចិត្តចូលជាសមាជិកសហជីពនេះក្នុងពេលកំពុងស្នើសុំចុះបញ្ជីកា ត្រូវបានការការពារដូចគ្នានឹងប្រតិភូបុគ្គលិកដែរ។ ការការពារ នេះមានរយៈពេលរហូតដល់៣០ថ្ងៃ ក្រោយកាលបរិច្ឆេទនៃការចុះបញ្ជីកាសហជីព"*។

ផ្អែកលើខ្លឹមសារនៃបទប្បញ្ញត្តិការងារខាងលើ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា ស្ថាបនិក ឬកម្មករនិយោជិតដែលស្ម័គ្រចិត្តចូលជាសមាជិកសហជីព គឺត្រូវបានទទួលការការពាររហូតដល់៣០ថ្ងៃក្រោយ កាលបរិច្ឆេទនៃការចុះបញ្ជីកាសហជីព។

មាត្រា ២៩៣ កថាខ័ណ្ឌទី១ នៃច្បាប់ស្តីពីការងារចែងថា *"រាល់ការបញ្ឈប់ប្រតិភូបុគ្គលិក ឬរាល់ការបញ្ឈប់បេក្ខជនណាមួយពីការងាររបស់ខ្លួនអាចធ្វើទៅបានលុះត្រាតែមានការយល់ព្រមពីអធិការការងារ ..."*។

ផ្អែកលើខ្លឹមសារនៃមាត្រា ២៩៣ នៃច្បាប់ស្តីពីការងារខាងលើ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា រាល់ការបញ្ឈប់កម្មករនិយោជិតដែលទទួលបានការការពារ និយោជកត្រូវមានការអនុញ្ញាតពីអធិការការងារ និងរដ្ឋមន្ត្រីទទួលបន្ទុកវិស័យការងារ។ មានន័យថា អធិការការងារមានតួនាទីពិចារណា ស្រាវជ្រាវ និងសម្រេចផ្តល់ការអនុញ្ញាត ឬបដិសេធចំពោះសំណើរបស់និយោជក ដែលសុំបញ្ឈប់ថ្នាក់ដឹកនាំសហជីពក្នុងរយៈពេលមួយខែយ៉ាងយូរក្រោយទទួលពាក្យបណ្តឹង។ (សូមមើលសេចក្តីបង្គាប់អាជ្ញាកណ្តាលលេខ *១៤៩/០៨-ខេមបូ ហាន់ស៊ើ ហេតុផលចំណុចវិវាទទី ១ និងលេខ ១៧៥/០៩-អាជ្ញាធរអប្សរា ហេតុផលចំណុចវិវាទទី២*)។

នៅសេចក្តីបង្គាប់មុនៗ ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានបកស្រាយថា ដើម្បីទទួលបានការការពារកម្មករនិយោជិតត្រូវបំពេញ *"លក្ខខណ្ឌចំនួន ៣ ដែលរួមមាន (១) កម្មករនិយោជិត គឺជាកម្មករនិយោជិតដែលកំណត់ក្នុងប្រកាសលេខ ៣០៥ (២) ការបញ្ឈប់ពីការងារស្ថិតនៅក្នុងពេលដែលពួកគេបានទទួលនូវការការពារ និង (៣) កម្មករនិយោជិតត្រូវជូនដំណឹងដល់និយោជកអំពីឈ្មោះអ្នកដែលត្រូវទទួលការការពារតាមគ្រប់មធ្យោបាយ ដែលទុកជាបានការ។"* (សូមមើលសេចក្តីបង្គាប់អាជ្ញាកណ្តាលលេខ *៥០/០៥-ហ្វូធ្យូន ហេតុផលចំណុចវិវាទទី១, លេខ ៦៤/០៥-ជាន វ៉ៃ ហេតុផលចំណុចវិវាទទី១, លេខ ០៧/០៦-ដាយ យ៉ាំង ហេតុផលចំណុចវិវាទទី១, លេខ ០៥/០៦-ប្រ៊ែនដ៏ដាយអ៊ីម៉ិន ស៊ីធី ហេតុផលចំណុចវិវាទទី ១ និងលេខ ១៤៨/០៧-ប៉ាយ ហ៊ឺ*)។

យោងតាមអង្គហេតុ កម្មការិនី ញាណ ថងម៉ា កម្មការិនី សៀម សុខលី និងកម្មការិនី ឯក សារី គឺជាកម្មករនិយោជិតដែលកំណត់នៅក្នុងប្រកាស៣០៥ ពោលគឺសុទ្ធសឹងតែជាបេក្ខជនឈរឈ្មោះបោះឆ្នោតជ្រើសរើសថ្នាក់ដឹកនាំសហជីព ដូចនេះ គឺលក្ខខណ្ឌទី ១ ត្រូវបានបំពេញ។ កម្មករនិយោជិតបានទទួលបានបង្កាន់ដៃស្នើសុំចុះបញ្ជិកានៅថ្ងៃទី១៤ ខែតុលា ឆ្នាំ២០១១ ហើយកម្មករនិយោជិតទាំងនោះត្រូវបានក្រុមហ៊ុនបញ្ឈប់នៅ ថ្ងៃទី២២ ខែតុលា ឆ្នាំ ២០១១ ពោលគឺថ្ងៃបញ្ឈប់នេះ គឺស្ថិតនៅក្រោមការពាររបស់ច្បាប់ក្នុងពេលកំពុងស្នើសុំចុះបញ្ជិកា។ ហេតុនេះ លក្ខខណ្ឌទី២ ត្រូវបានបំពេញ។ យោងតាមអង្គហេតុ កម្មករនិយោជិតបានជូនដំណឹងទៅនិយោជកពីបេក្ខភាពអ្នក

THE ARBITRATION COUNCIL

ដែលជាជាប់ឆ្នោតនៅថ្ងៃទី១០ ខែតុលា ឆ្នាំ២០១១ រដ្ឋបាលក្រុមហ៊ុនមិនទទួលទេដោយគ្រាន់តែថតចំលងទុកដោយមិនព្រមចុះហត្ថលេខាលើលិខិតជូនដំណឹងឡើយ។ មួយវិញទៀត និយោជកបានធ្វើការជំទាស់ទៅនឹងបេក្ខភាពថ្នាក់ដឹកនាំសហជីពទៅនាយកដ្ឋានវិវាទការងារទៀតផង។ ហេតុនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើថា និយោជក គឺបានដឹងពីសមាសភាពកម្មករនិយោជិតដែលជាសមាជិកសហជីព។ ដូច្នេះ លក្ខខណ្ឌទី៣ ត្រូវបានបំពេញ។

ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា កម្មការិនី ញាណ ផងម៉ា កម្មការិនី សៀម សុខលី និង កម្មការិនី ឯក សារី បានឈរឈ្មោះជាបេក្ខជនសម្រាប់ការបោះឆ្នោតជ្រើសរើសថ្នាក់ដឹកនាំសហជីព ដូចនេះកម្មករនិយោជិតទាំង ៣ នាក់នេះ គឺជាស្ថាបនិកសហជីព។ យោងតាមច្បាប់ និយោជកត្រូវសុំការអនុញ្ញាតពីអធិការងារជាមុនសិនមុននឹងធ្វើការបញ្ឈប់ស្ថាបនិកសហជីពក្នុងពេលកំពុងស្នើសុំចុះបញ្ជិកា ដែលត្រូវបានការពារនេះ។

នៅក្នុងសំណុំរឿងនេះ និយោជកមិនបានសុំការអនុញ្ញាតពីអធិការការងារមុននោះទេ មុននឹងបញ្ឈប់កម្មករនិយោជិតទាំង ៣ នាក់នេះ ។ ដូចនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា ការបញ្ឈប់កម្មករនិយោជិតទាំង ៣ នាក់ ដែលទទួលបានការការពារនេះ និយោជកមិនបានធ្វើស្របទៅតាមមាត្រា ២៩៣ នៃច្បាប់ស្តីពីការងារ និង ប្រកាស ៣០៥ ទេ។

ដូច្នេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលបង្គាប់ឱ្យនិយោជកទទួលយក កម្មការិនី ញាណ ផងម៉ា កម្មការិនី សៀម សុខលី និងកម្មការិនី ឯក សារី ឱ្យចូលធ្វើវិញ ព្រមទាំងគិតរំលឹកប្រាក់ឈ្នួល ចាប់ពីថ្ងៃបញ្ឈប់រហូតដល់ថ្ងៃចូលធ្វើការវិញ។

នៅក្នុងសវនាការ ភាគីកម្មករនិយោជិតបានលើកឡើងថា ការបញ្ឈប់កម្មករនិយោជិតទាំង ៣ នាក់ មានការរើសអើងសហជីព ព្រោះពួកគាត់ជាថ្នាក់ដឹកនាំសហជីពខ្មែរ។

មាត្រា ១២ នៃច្បាប់ស្តីពីការងារចែងថា *"....គ្មាននិយោជកណាម្នាក់ អាចយកបញ្ហា...ការចូលជាសមាជិកសហជីពកម្មករនិយោជិត ឬ ការធ្វើសកម្មភាពក្នុងសហជីពដើម្បីជាលេសធ្វើសេចក្តីសំរេចអំពី:... វិន័យ ឬការផ្តាច់កិច្ចសន្យាការងារ..."*។

មាត្រា ២៧៩ នៃច្បាប់ស្តីពីការងារចែងថា *"ត្រូវហាមឃាត់ចំពោះនិយោជកគ្រប់រូប មិនឱ្យយកការចូលរួមជាសមាជិករបស់សហជីព ឬការចូលរួមក្នុងសកម្មភាពរបស់សហជីពនៃកម្មករនិយោជិត ដើម្បីធ្វើការសម្រេចចិត្តក្នុងការជ្រើសរើសឱ្យចូលធ្វើការងារ ការដឹកនាំ និងការបែងចែកការងារ ការតំឡើងថ្នាក់ ការផ្តល់ប្រាក់ឈ្នួល និងការផ្តល់ផលប្រយោជន៍ វិធានការដាក់វិន័យ និងការបណ្តេញចេញ"* ។

នៅក្នុងសេចក្តីបង្គាប់មុនៗ ក្រុមប្រឹក្សាអាជ្ញាកណ្តាលធ្វើការបកស្រាយយ៉ាងស៊ីសង្វាក់គ្នាថា *"ជាទូទៅក្រុមប្រឹក្សាអាជ្ញាកណ្តាលបានកំណត់ថា ភាគីដែលធ្វើការចោទប្រកាន់មានបន្ទុកភស្តុតាងក្នុងការបង្ហាញមកក្រុមប្រឹក្សាអាជ្ញាកណ្តាលដើម្បីគាំទ្រការចោទប្រកាន់ទាំងនេះ"*។ (សូមមើលសេចក្តីបង្គាប់អាជ្ញាកណ្តាលលេខ *១២៣/០៧-អ៊ី ហ្គាមេន ហេតុផលចំណុចវិវាទទី១ និងលេខ ១៤៨/០៧-ជ៉ាយ ហ៊ី និងលេខ ៣៤/១១-លីម ឡាញ ហេតុផលចំណុចវិវាទទី៧* )។

ទាក់ទងនឹងភស្តុតាងនៃការរើសអើងសហជីព ជាទូទៅ ក្រុមប្រឹក្សាអាជ្ញាកណ្តាលពិចារណាលើការឆ្លើយបំភ្លឺនៅក្នុងសវនាការ និងធ្វើការពិនិត្យទៅលើភស្តុតាងដែលពាក់ព័ន្ធទៅនឹងសំណុំរឿងដើម្បីកំណត់ថាមានការរើសអើង



THE ARBITRATION COUNCIL

សហជីពកើតមានឡើងដែរ ឬទេ។ (សូមមើលសេចក្តីបង្គាប់អាជ្ញាកណ្តាលលេខ *១៧/០៧-ឆាមចិចថាយ ហេតុផលចំណុចវិវាទទី ១ និងលេខ ១៤៨/០៧-ចាំយហុី*)។

ក្រុមប្រឹក្សាអាជ្ញាកណ្តាលនៅក្នុងសំណុំរឿងនេះ ក៏យល់ស្របនឹងការបកស្រាយរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាលនៅក្នុងសំណុំរឿងខាងលើដែរ។ នៅក្នុងករណីនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តារកឃើញថា និយោជកបានបញ្ឈប់កម្មកនិយោជិតទាំង ៣ នាក់ នៅថ្ងៃតែមួយ គឺថ្ងៃទី២២ ខែតុលា ឆ្នាំ២០១១ បន្ទាប់ពីកម្មករនិយោជិតបានជូនដំណឹងទៅនិយោជកពីបេក្ខភាពដែលជាអ្នកជាប់ឆ្នោតនៅថ្ងៃទី១០ ខែតុលា ឆ្នាំ២០១១ ហើយនិយោជកក៏បានដឹងថា កម្មករទាំងបីនាក់ ជាថ្នាក់ដឹកនាំសហជីពដែរ។ ហេតុនេះហើយ និយោជកបញ្ឈប់ពួកគាត់ទាំងបីនាក់ បង្ហាញថា ការបញ្ឈប់នេះមានការទាក់ទងនឹងការរើសអើងសហជីព ។

ដូច្នេះសរុបមក ក្រុមប្រឹក្សាអាជ្ញាកណ្តាលបង្គាប់ឱ្យនិយោជកទទួលយក កម្មការិនី ញាណ ថងម៉ា កម្មការិនី សៀម សុខលី និងកម្មការិនី ឯក សារី ឱ្យចូលធ្វើការវិញ ព្រមទាំងគិតរំលឹកប្រាក់ឈ្នួលចាប់ពីថ្ងៃបញ្ឈប់រហូតដល់ថ្ងៃចូលធ្វើការវិញ និងបញ្ឈប់ការរើសអើងសហជីព។

យោងតាមអង្គហេតុ អង្គច្បាប់ និងហេតុផលដូចបានបញ្ជាក់ខាងលើ ក្រុមប្រឹក្សាអាជ្ញាកណ្តាលសម្រេចចេញសេចក្តីបង្គាប់ ដូចតទៅ ៖

## សម្រេច និង បង្គាប់

១- សេចក្តីបង្គាប់ទាក់ទងនឹងវិវាទអំពីសិទ្ធិ ៖

ចំណុចវិវាទទី១ ៖

- បង្គាប់ឱ្យនិយោជកទទួលយកកម្មការិនី ញាណ ថងម៉ា កម្មការិនី សៀម សុខលី និងកម្មការិនី ឯក សារី ឱ្យចូលធ្វើការវិញ ព្រមទាំងគិតរំលឹកប្រាក់ឈ្នួល ចាប់ពីថ្ងៃបញ្ឈប់ រហូតដល់ថ្ងៃចូលធ្វើការវិញ និងបញ្ឈប់ការរើសអើងសហជីព។

ប្រភេទនៃសេចក្តីបង្គាប់ទាក់ទងនឹងវិវាទអំពីសិទ្ធិ ៖

សេចក្តីបង្គាប់របស់ក្រុមប្រឹក្សាអាជ្ញាកណ្តាលនៅក្នុងសេចក្តីសម្រេចផ្នែកទី១នេះ នឹងក្លាយជាស្ថាពរភ្លាម ហើយអនុវត្តចំពោះភាគីតែម្តង ដោយយោងតាមអនុស្សារណៈនៃការយោគយល់គ្នា ចុះថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ២០១០ ។

២- សេចក្តីបង្គាប់ទាក់ទងនឹងវិវាទអំពីផលប្រយោជន៍: គ្មាន

ប្រភេទនៃសេចក្តីបង្គាប់ទាក់ទងនឹងវិវាទអំពីផលប្រយោជន៍:

សេចក្តីបង្គាប់របស់ក្រុមប្រឹក្សាអាជ្ញាកណ្តាលនៅក្នុងសេចក្តីសម្រេចផ្នែកទី២នេះ នឹងក្លាយជាស្ថាពរ បន្ទាប់ពីថ្ងៃជូនដំណឹងអំពីសេចក្តីបង្គាប់ចំនួន ០៨ ថ្ងៃ បើសិនជាមិនមានភាគីណាមួយដាក់ពាក្យជំទាស់ជាលាយលក្ខណ៍អក្សរទៅរដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ តាមរយៈលេខាធិការដ្ឋាននៃក្រុមប្រឹក្សាអាជ្ញាកណ្តាលក្នុងរយៈពេលនេះទេ។

THE ARBITRATION COUNCIL

**ហត្ថលេខារបស់សមាជិកក្រុមអាជ្ញាកណ្តាល**

អាជ្ញាកណ្តាលជ្រើសរើសដោយភាគីនិយោជក ៖

ឈ្មោះ ៖ **អ៊ឹង សុទ្ធី**

ហត្ថលេខា: --------------------------------

អាជ្ញាកណ្តាលជ្រើសរើសដោយភាគីកម្មករនិយោជិត ៖

ឈ្មោះ ៖ **លីវ សុវណ្ណា**

ហត្ថលេខា: --------------------------------

ប្រធានក្រុមអាជ្ញាកណ្តាល ៖

ឈ្មោះ ៖ **ម៉ែន ម៉ុនឈា**

ហត្ថលេខា: --------------------------------